ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

មន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរីគិរី ថ្ងៃ............ ខែ.................... ឆ្នាំច សំរឹទ្ធស័កព.ស២៥៦២
ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម រតនគិរី.ថ្ងៃទី......... ខែ.......... ឆ្នាំ ២០១៩

# របាយការណ៍
# សកម្មភាពការងារអភិវឌ្ឍន៍សហគមន៍កសិកម្ម
# ប្រចាំឆ្នាំ២០១៨

## ១.ស្ថានភាពរួម

ក្នុងរយះពេល០១ ឆ្នាំ ២០១៨ នេះ សកម្មភាពការងារសហគមន៍កសិកម្ម ដែល ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម អនុវត្តបាន មានលទ្ធផលដូចខាងក្រោមៈ

- សកម្មភាពសន្និបាតប្រចាំ២០១៧របស់សហគមន៍កសិកម្ម
- វគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំសហគមន៍កសិកម្ម
- សកម្មភាពចូលរួមសិក្ខាសាលារបស់មន្ត្រីនិងថ្នាក់ដឹកនាំការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម
- សកម្មភាពគាំទ្រសហគមន៍កសិកម្ម
- សកម្មភាពចូលរួមផ្សេង

## ២.ស្ថានភាពមន្ត្រី

មន្ត្រីបម្រើការងារនៅការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្មមានចំនួន ០៤នាក់ /ស្រីចំនួន០០នាក់ ក្នុងនោះ ៖

- ថ្នាក់បរិញ្ញាបត្រ ចំនួន ០៣ នាក់
- ថ្នាក់បរិញ្ញាបត្ររង ចំនួន ០១ នាក់

## ៣.សម្ភារៈការិយាល័យ

- តុ ចំនួន០២ .កៅអី ចំនួន០៤ .កុំព្យូទ័រ ចំនួន០១ .ទូដាក់ឯកសារ ចំនួន០១ .ម៉ាស៊ីនព្រីន ចំនួន០១

## ៤.លទ្ធផលការងារនិងសមិទ្ធិផលសម្រេចបាន

### ៤.១ មហាសន្និបាតបូកសរុបប្រចាំឆ្នាំសហគមន៍កសិកម្ម

- នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ លោក ឈាង ណូរ៉ា បានចូលរួម រៀបចំមហាសន្និបាត សាមញ្ញស្តីពីការបញ្ចូល សមាជិក ក្រុមសន្រ្ទិបស់អង្គការអាយ ស៊ី អេស អូ ចូលជាសមាជិករបស់សហគមន៍កសិកម្មអភិវឌ្ឍន៍លុងឃុង ស្ថិតនៅភូមិលុងឃុង ឃុំលុងឃុង ស្រុកបរកែវ ខេត្តរតនគិរី ។

- នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ លោកឈាង ណូរ៉ា ចូលរួម រៀបចំមហាសន្និបាតសាមញ្ញស្តីពី ការបញ្ចូលសមាជិកក្រុមសន្សំចូលជាសមាជិករបស់សហគមន៍កសិកម្មចម្រុះល្អីនក្រែន ស្ថិតនៅភូមិល្អីនក្រែន ឃុំអូរជុំ ស្រុកអូជុំ ខេត្តរតនគិរី
- នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ លោក ឈាង ណូរ៉ា និងលោក ផាន ភា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំឆ្នាំ០១៧របស់សហគមន៍កសិកម្មឧត្តមមានជ័យដីឡូតិ៍ ស្ថិតនៅភូមិដីឡូតិ៍ ឃុំជ័យឧត្តម ស្រុកលំផាត់ ដែលមានអ្នកចូលរួម៩៦នាក់ ស្រី៥៧នាក់។
- នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨ លោក ឈាង ណូរ៉ាចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំ ឆ្នាំ០១៧ របស់សហគមន៍កសិកម្មភូមិក្រេះដីក្រហម ស្ថិតនៅភូមិក្រេះ ឃុំប៉ូយ ស្រុកអូរជុំ ដែលមានអ្នកចូលរួមចំនួន៧០ នាក់ ស្រី៣០ នាក់។
- នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ លោក ឈាង ណូរ៉ា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំឆ្នាំ០១៧ របស់ សហគមន៍កសិកម្មសិរីមង្គលរុងរឿង ស្ថិតនៅភូមិស្រែពកធំ ឃុំសិរីមង្គល ស្រុកកូនមុំ ខេត្តរតនគិរី ដែលមាន អ្នកចូលរួម ៣៧នាក់ ស្រី៣២ នាក់។
- នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ លោកង៉ែត ធារ៉ា និលោកឈាង ណូរ៉ា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំឆ្នាំ០១៧របស់សហគមន៍កសិកម្មភូមិកែប្រែជីវភាព ស្ថិតនៅភូមិ០១ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី ដែលមានអ្នកចូលរួម៤១ នាក់ ស្រី ១៩នាក់។
- នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ លោកង៉ែត ធារ៉ា និលោកឈាង ណូរ៉ា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំឆ្នាំ០១៧ របស់សហគមន៍កសិកម្មកាត់បន្ថយភាពក្រីក្រ នៅភូមិតឹន ឃុំ តឹន ស្រុកកូនមុំ ខេត្តរតនគិរី ដែល មានអ្នកចូលរួម៦០ នាក់ ស្រី២៩ នាក់។
- នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨ លោកង៉ែត ធារ៉ា និលោកឈាង ណូរ៉ា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំ ឆ្នាំ០១៧ របស់សហគមន៍កសិកម្មសាមគ្គីម៉ឺនចាំង នៅភូមិម៉ឺនចាំង ឃុំតឹន ស្រុកកូនមុំខេត្តរតនគិរី ដែលមានអ្នកចូលរួម៦៦ នាក់ ស្រី២៦ នាក់។
- នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨ លោកង៉ែត ធារ៉ា និលោកឈាង ណូរ៉ា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំឆ្នាំ០១៧ របស់សហគមន៍កសិកម្មកសិករសាមគ្គី នៅភូមិម៉ាលិក ឃុំម៉ាលិក ស្រុកអណ្តូងមាស ខេត្តរតនគិរី ដែល មាន អ្នកចូលរួម៣៦ នាក់ ស្រី០៨ នាក់។
- នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ លោក ឈាង ណូរ៉ា និង លោក ជា នាត ចូលរួមពិធី មហាសន្និបាតបូកសរុបប្រចាំឆ្នាំ០១៧ របស់សហគមន៍កសិកម្មរស្មីមានជ័យ នៅភូមិ០១ ឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរីដែល មានអ្នកចូលរួមចំនួន៦០ នាក់ ស្រី៣៣ នាក់។
- ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៨ ឈាង ណូរ៉ា ចូលរួមពិធីមហាសន្និបាតបូកសរុបប្រចាំឆ្នាំ២០១៧ របស់សហគមន៍ កសិកម្មចម្រុះរង៉ោលដូងល្អីនកាំមីស នៅភូមិល្អីនកាំមីស ឃុំអូរជុំ ស្រុកអូរជុំ ខេត្តរតនគិរី ដែលមានអ្នក ចូលរួមចំនួន៣១នាក់ ស្រី១៦នាក់ ។

## ៤.២ សកម្មភាពចូលរួមសិក្ខាសាលារបស់មន្ត្រីនិងថ្នាក់ដឹកនាំការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម

- ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១៧ លោកសយ សូណា និងលោក ឈាង ណូរ៉ា បានចូលរួមប្រជុំពិគ្រោះយោបល់ លើកទី០៣ ស្តីពីកិច្ចអភិវឌ្ឍន៍សហគមន៍កសិកម្មនៅ កម្ពុជារបស់ បណ្តាញភ្នាក់ងារ អភិវឌ្ឍន៍សហគមន៍កសិកម្ម នៅអគ្គនាយកដ្ឋានកសិកម្ម ដែលមានអ្នកចូលរួម ចំនួន៨៨នាក់ ស្រី១២ នាក់ ។
- ថ្ងៃទី ២៥-២៨ ខែធ្នូ ឆ្នាំ ២០១៧ លោក ឈាង ណូរ៉ា និងលោកផាន ភា បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រសិទ្ធភាពការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលនៅសណ្ឋាគារភ្នំប្រុស ទីរួមខេត្តកំពង់ចាម។
- ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៧ លោកង៉ែត ធារ៉ា និងលោក ឈាង ណូរ៉ា បានចូលរួមប្រជុំពិគ្រោះ យោបល់សេចក្តីព្រាងអនុក្រឹតស្តីពីការលើកទឹកចិត្តនិងសិទ្ធិអនុគ្រោះចំពោះសហគមន៍កសិកម្ម នៅអគ្គនាយកដ្ឋានកសិកម្ម ។
- ថ្ងៃទី១៩-២២ ខែកុម្ភៈ ឆ្នាំ២០១៨ លោកង៉ែត ធារ៉ា និងលោក ឈាង ណូរ៉ា បានចូលរួមសន្និបាតសហគមន៍កសិកម្មទូទាំងប្រទេសនៅខេត្តបាត់ដំបងដែលមានអ្នកចូលរួមសរុប៨៧នាក់ ស្រី១៣នាក់ ។
- ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨ លោក ង៉ែត ធារ៉ា អនុប្រធានមន្ទីរ រួមជាមួយលោក ឈាង ណូរ៉ា និងមន្ត្រី០១រូបបានចូលរួមសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីនីតិវិធីបង្កើតនិងចុះបញ្ជីសហគមន៍កសិកម្ម សហភាពសហគមន៍កសិកម្ម និងសម្ព័ន្ធសហគមន៍កសិកម្មកម្ពុជា នៅអគ្គនាយកដ្ឋានកសិកម្ម ដែលមានអ្នកចូលរួមចំនួន៨៨នាក់ ស្រី១២នាក់ ។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ លោក ផាន ភា និង លោកជា នាត ជាមន្ត្រីចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកិច្ចអភិវឌ្ឍន៍សហគមន៍កសិកម្មនៅខេត្តបាត់ដំបង ដែលមានអ្នកចូលរួមសរុប ៥៧ នាក់ ស្រី ០៨នាក់ ។
- ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៨ មន្ត្រី០២រូប បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពីអត្ថប្រយោជន៍មន្ត្រីរាជការ នៅសាលប្រជុំមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួមចំនួន៤៦នាក់ ស្រី០៥នាក់ ។
- ថ្ងៃទី០៥ដល់០៦ ខែកញ្ញា ឆ្នាំ២០១៨ អនុប្រធានការិយាល័យបានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីវិធីសាស្រ្ត និងបច្ចេកវិទ្យាថ្មីនៃការគ្រប់គ្រងបៃតងសម្រាប់អភិវឌ្ឍន៍កសិកម្មនៅទន្លេបាសាក់០២ ដែលមានអ្នកចូលរួមសរុបប្រមាណ២៣០នាក់ ។
- ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ មន្ត្រី០២រូបបានចូលរួមវគ្គបំប៉នស្តីពីការធ្វើបច្ចុប្បន្នភាពស្ថាប័ន និងភ្នាក់ងារផ្សព្វផ្សាយកសិកម្ម នៅមន្ទីរកសិកម្ម ដែលមានអ្នកចូលរួម១៥នាក់ ស្រី០១ នាក់ ។
- ថ្ងៃទី១៣ដល់១៤ ខែកញ្ញា ឆ្នាំ២០១៨ អនុប្រធានការិយាល័យ និងមន្ត្រី០១រូប ចូលរួមវគ្គសិក្ខាសាលាស្តីពីប្រព័ន្ធតាមដាន និងវាយតម្លៃថវិកាកម្មវិធី ដែលមានអ្នកចូលរួមសរុបចំនួន៤៤នាក់ ស្រី០៦នាក់ ។

- ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ ចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តង់ដាសហគមន៍កម្ពុជា និងស្តង់ដាសហគមន៍ទេសចរណ៍អាស៊ាន នៅសណ្ឋាគាររតនគិរី ក្រោមអធិតីភាពឯ.ឧ តុប សុភ័កអនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ ដោយមានអ្នកចូលរួមសរុបប្រមាណ១៣៥នាក់ ។
- ថ្ងៃទី១៦-១៩ ខែតុលា ឆ្នាំ២០១៨ អនុប្រធានការិ.០១រូប និងមន្ត្រី០១រូបបានដឹកនាំថ្នាក់ដឹកនាំសហគមន៍កសិកម្មចំនួន០២រូប ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការចុះបញ្ជីគណនេយ្យសម្រាប់សហគមន៍កសិកម្ម នៅខេត្តកំពង់ធំ ដែលមានអ្នកចូលរួមប្រមាណ៤២នាក់ ស្រី១៨នាក់ ។
- ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.និងមន្ត្រី០១រូបដឹកនាំថ្នាក់ដឹកនាំ សហគមន៍កសិកម្មចំនួន០៨រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីកិច្ចអភិវឌ្ឍន៍សហគមន៍កសិកម្ម នៅខេត្តកំពង់ចាមដែលមានអ្នកចូលរួមប្រមាណ១០០នាក់ ស្រី២៤នាក់ ។
- ថ្ងៃទី០៧-០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ មន្ត្រី០២រូប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើឯកសារព្រាងស្តីពី គោលគំនិតសហគមន៍កសិកម្ម នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួម១១០នាក់ ។
- ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងសហគ្រាស និងការផ្តួចផ្តើមអោយស្ត្រីប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មានវិទ្យា ក្នុងចលនាភូមិ១ផលិតផល១ នៅសណ្ឋាគាររតនស៊ីធី ខេត្តរតនគិរី ដែលមានសិក្ខាកាមចូលរួមប្រមាណ៤២នាក់ ស្រី១២នាក់ ។
- ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ២០១៧ លោកង៉ែត ធារ៉ា និងលោក ឈាង ណូរ៉ា បានចូលរួមប្រជុំពិគ្រោះ យោបល់លើកទី០៤ ស្តីពីកិច្ចអភិវឌ្ឍន៍សហគមន៍កសិកម្ម នៅកម្ពុជារបស់ បណ្តាញភ្នាក់ងារអភិវឌ្ឍន៍សហគមន៍កសិកម្ម នៅអគ្គនាយកដ្ឋានកសិកម្ម ដែលមានអ្នកចូលរួម ចំនួន៩៨នាក់ ស្រី១២ នាក់ ។

**៤.៣. វគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំសហគមន៍កសិកម្ម**

- ថ្ងៃទី២៣-២៥ ខែមេសា ឆ្នាំ២០១៨ មន្ត្រីចំនួន០២រូបចូលរួមសម្របសម្រួលវគ្គស្តីពីការគៀងគរថវិកាការគ្រប់គ្រងផែនការអាជីវកម្ម និងការត្រួតពិនិត្យនិងតាមដានដល់ថ្នាក់ដឹកនាំសហគមន៍ នៅសណ្ឋាគារសុល ឆេង ទីរួមខេត្តរតនគិរី ដែលមានអ្នកចូលរួមសរុប២៤នាក់ ស្រី០៥នាក់ ។
- ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ លោក ឈាង ណូរ៉ា អនុប្រធានការិយាល័យរួមជាមួយលោក ផាន ភាជាមន្ត្រីបានជួបប្រជុំជាមួយលោកអនុប្រធានសាខាអង្គការឌីភីអេប្រចាំខេត្តរតនគិរីអំពីការផ្តល់វគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំសហគមន៍កសិកម្មពីការសរសេររបាយការណ៍ និងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំនៅអង្គការឌីភីអេខេត្តរតនគិរី។
- ថ្ងៃទី២៨-៣០ ខែឧសភា ឆ្នាំ២០១៨ សម្របសម្រួលវគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងសមាជិកសសហគមន៍កសិកម្មចំនួន០២សហគមន៍ស្តីពីអភិបាលកិច្ចល្អ ការគ្រប់គ្រងហិរញ្ញវត្ថុ និង វដ្តនៃការគ្រប់គ្រង គម្រោង ដែលមានអ្នកចូលរួមសរុប៣១នាក់ ស្រី១១នាក់ ។

- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ សម្របសម្រួលវគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំសហគមន៍កសិកម្ម ចំនួន១៨សហគមន៍ស្តីពីការសរសេររបាយការណ៍ និងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលមានអ្នកចូលរួមសរុប៣២នាក់ ស្រី០២នាក់ ។
- ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៨ មន្ត្រីការិយាល័យចំនួន០២រូប បានសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពីលក្ខន្តិកៈសហគមន៍កសិកម្ម និងកែសម្រួលគម្រោងស្នើសុំថវិការបស់សហគមន៍កសិកម្មចម្រុះអភិវឌ្ឍន៍លុងឃុង និងសហគមន៍កសិកម្មចម្រុះរតនល្មីនក្រែន នៅស្នាក់ការអង្គការICSOខេត្តរតនគិរី ដោយមានអ្នកចូលរួម៧៤នាក់ ស្រី២៥នាក់ ។
- ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ មន្ត្រី០២រូបបានចូលរួមសម្របសម្រួលវគ្គស្តីពីប្រសិទ្ធិភាព និងនិតិវិធីគ្រប់គ្រងថវិកាសហគមន៍កសិកម្ម នៅស្នាក់ការអង្គការICSOខេត្តរតនគិរី ដែលមានអ្នកចូលរួមសរុប៣៦នាក់ ស្រី១៣នាក់ ។
- ថ្ងៃទី១៩-២០ ខែវិច្ឆិកា ឆ្នាំ២០១៨ មន្ត្រី០២រូបបានសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីអភិបាលកិច្ចល្អ និងការគ្រប់គ្រងហិរញ្ញវត្ថុដល់ថ្នាក់ដឹកនាំសហគមន៍កសិកម្មចំនួន០២សហគមន៍ដោយមានអ្នកចូលរួមចំនួន ៣៥នាក់ ស្រី០៥នាក់ គាំទ្រដោយអង្គការICSO។

**៤.៤. សកម្មភាពគាំទ្រសហគមន៍កសិកម្ម**

- ថ្ងៃទី១៧-១៩ ខែមករា ឆ្នាំ២០១៨ បានចូលរួមជួយបិទបញ្ជីគណនេយ្យ សហគមន៍កសិកម្មវឌ្ឍនៈសង្គម សហគមន៍កសិកម្មអភិវឌ្ឍន៍កសិកម្មរស្មីមានជ័យ សហគមន៍កសិកម្មកសិករភ្លឺថ្លា សហគមន៍កសិកម្មពន្លឺកសិករ ស្ថិនៅឃុំត្រពាំងច្រេស ស្រុកកូនមុំ ខេត្តរតនគិរី។
- ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ បានចូលរួមជួយបិទបញ្ជីគណនេយ្យ សហគមន៍កសិកម្មពន្លឺអភិវឌ្ឍន៍ភូមិ១ ស្ថិនៅឃុំត្រពាំងក្រហម ស្រុកកូនមុំ ខេត្តរតនគិរី។
- ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨ បានចូលរួមប្រមូលប្រាក់សមាជិកភាព និងប្រាក់ភាគហ៊ុននៅសហគមន៍កសិកម្មអភិវឌ្ឍន៍ភូមិលុងឃុង ស្រុកបរកែវ ខេត្តរតនគិរី និងសហគមន៍កសិកម្មចម្រុះល្មីនក្រែន ភូមិល្មីនក្រែន ឃុំអូរជុំ ស្រុកអូរជុំ ដែលបានគាំទ្រដោយអង្គការ ICSO ។
- ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៨ បានចូលរួមជួយបិទបញ្ជីគណនេយ្យ សហគមន៍កសិកម្មភូមិថ្មីជ័យជុំនះ និងសហគមន៍កសិកម្មដីឡូតិ៍មានរិទ្ធិ ស្ថិតនៅឃុំជ័យឧត្តម ស្រុកលំផាត់ ខេត្តរតនគិរី។
- ថ្ងៃទី១២-១៣ ខែកុម្ភៈ ឆ្នាំ២០១៨ បានចូលរួមបានចូលរួមជួយបិទបញ្ជីគណនេយ្យ សហគមន៍កសិកម្មតេនទុងជ័យ សហគមន៍កសិកម្មចម្រុះកាតែរុងរឿង សហគមន៍កសិកម្មចម្រុះភូមិអ៊ុន សហគមន៍កសិកម្មចម្រុះភូមិឡៃ សហគមន៍កសិកម្មភូមិសោមគល់ សហគមន៍កសិកម្មចម្រុះភូមិប៉ាអរ ស្ថិតនៅស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។

- ថ្ងៃទី១៤-១៥ ខែកុម្ភៈ ឆ្នាំ២០១៨ បានចូលរួមជួយបិទបញ្ជីគណនេយ្យ សហគមន៍កសិកម្មល្លឺនក្រែន សហគមន៍កសិកម្មល្អឺនជង សហគមន៍កសិកម្មចម្រុះធួយទំរតនៈ សហគមន៍កសិកម្មភូមិឯកភាព សហគមន៍កសិកម្មល្លឺនកាមីស សហគមន៍កសិកម្មតងប្លេង ស្ថិតនៅស្រុកអូរជុំ ខេត្តរតនគិរី។
- ថ្ងៃទី២៦-២៧ ខែកុម្ភៈ ឆ្នាំ២០១៨ មន្ត្រី០២រូបបានចុះបិទបញ្ជីសហគមន៍កសិកម្មចំនួន០៥សហគមន៍ នៅឃុំអូរជុំ០៣សហគមន៍ ឃុំឯកភាព ០១សហគមន៍ ឃុំចាអ៊ុង០១សហគមន៍ ស្រុកអូរជុំ ខេត្តរតនគិរី មានថ្នាក់ដឹកនាំសហគមន៍កសិកម្មចូលរួមចំនួន១៥នាក់ ស្រី០១នាក់ ។
- ថ្ងៃទី០៥-០៦ ខែមីនា ឆ្នាំ២០១៨ មន្ត្រី០២រូបបានចុះបិទបញ្ជីសហគមន៍កសិកម្មចំនួន០៤សហគមន៍ នៅឃុំកិៈចុង០៣សហគមន៍ ឃុំសើុង ០១សហគមន៍ ស្រុកបរកែវ ខេត្តរតនគិរី មានថ្នាក់ដឹកនាំសហគមន៍កសិកម្មចូលរួមចំនួន០៨នាក់ ស្រី០០នាក់ ។
- ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ បានចូលរួមជួយបិទបញ្ជីគណនេយ្យ សហគមន៍កសិកម្មលំផាត់ជោគជ័យ សហគមន៍កសិកម្មអូរកានមានជ័យ សហគមន៍កសិកម្មកាំឆ្លិញមានលាភ ស្ថិតនៅស្រុកលំផាត់ ខេត្តរតនគិរី។
- ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨ បានចូលរួមសម្របសម្រួលការប្រជុំពង្រឹងលក្ខន្តិកៈ សហគមន៍កសិកម្មចម្រុះល្អឺនក្រែនស្ថិតនៅភូមិល្អឺនក្រែន ឃុំអូរជុំ ស្រុកអូរជុំ ដែលមានអ្នកចូលរួមសរុប៣៨នាក់ ស្រី២៦នាក់ ។
- ថ្ងៃទី០២-០៥ ខែមីនា ឆ្នាំ២០១៨ បានបញ្ចូលទិន្នន័យបច្ចុប្បន្នភាពសហគមន៍កសិកម្ម ចំនួន០៥ សហគមន៍ ។
- ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ អនុប្រធានការិយាល័យនិងមន្ត្រី០១រូបចូលរួមសម្រប សម្រួលប្រជុំរៀបចំសរសេរសំណើគម្រោង និងផែនការអាជីវកម្មរបស់សហគមន៍កសិកម្មចម្រុះល្អឺនក្រែន និង សហគមន៍កសិកម្មចម្រុះអភិវឌ្ឍន៍លុងយុង នៅភូមិល្អឺនក្រែន ឃុំអូរជុំ ស្រុកអូរជុំ និងភូមិលុងយុង ឃុំលុងយុង ស្រុកបរកែវ ដែលមានអ្នកសរុបចូលរួម៦០នាក់ ស្រី២១នាក់ ។
- ថ្ងៃទី២៨-៣០ ខែឧសភា ឆ្នាំ២០១៨ សម្របសម្រួលវគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងសមាជិកសហគមន៍កសិកម្មចំនួន០២សហគមន៍ស្តីពីអភិបាលកិច្ចល្អ ការគ្រប់គ្រងហិរញ្ញវត្ថុ និង វដ្តនៃការគ្រប់គ្រងគម្រោង ដែលមានអ្នកចូលរួមសរុប៣១នាក់ ស្រី១១នាក់ ។
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ សម្របសម្រួលវគ្គបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំសហគមន៍កសិកម្មចំនួន១៨សហគមន៍ស្តីពីការសរសេររបាយការណ៍ និងផែនការហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលមានអ្នកចូលរួមសរុបចំនួន៣២នាក់ ស្រី០២នាក់ ។
- ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ មន្ត្រីការិយាល័យចំនួន០២រូបបានសហការណ៍ជាមួយ អង្គការICSO សម្របសម្រួលពីការសរសេរគម្រោងស្នើសុំថវិកាសម្រាប់អភិវឌ្ឍន៍ជំនួញសហគមន៍កសិកម្មរបស់សហ

គមន៍កសិកម្មចម្រុះរតនល្មីនក្រែន និងសហគមន៍កសិកម្មចម្រុះអភិវឌ្ឍន៍លុងយុង នៅស្នាក់ការអង្គកា រICSO ដែលមានអ្នកចូលរួមចំនួន១២នាក់ ស្រី០២នាក់ ។

- ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ អនុប្រធានការិយាល័យបានប្រជុំពិភាក្សាជាមួយតំណាងអង្គការICSO ស្តីពីកម្មវិធីវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់សហគមន៍កសិកម្មចំនួន០២សហគមន៍ ។
- ថ្ងៃទី០៩ដល់១០ ខែសីហា ឆ្នាំ២០១៨ អនុប្រធានការិយាល័យនិងមន្ត្រីការិយាល័យចំនួន០១រូប បានចុះតាមដានប្រតិបត្តិការទុនរបស់សហគមន៍កសិកម្មពន្លឺអភិវឌ្ឍន៍ភូមិ០១ នៅភូមិ០១ ឃុំត្រពាំងក្រហម ស្រុកកូនមុំ ដែលមានអ្នកចូលរួមចំនួន០៦នាក់ ស្រី០១នាក់ ។
- ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៨ អនុប្រធានការិយាល័យនិងមន្ត្រីការិយាល័យចំនួន០១រូប បានចូលរួមប្រជុំធ្វើផែនការសកម្មភាពរបស់សហគមន៍កសិកម្មចម្រុះរតនល្មីនក្រែន និងសហគមន៍កសិកម្មចម្រុះអភិវឌ្ឍន៍លុងយុង នៅស្នាក់ការអង្គការICSOខេត្តរតនគិរី ដែលមានអ្នកចូលរួមចំនួន១២នាក់ ស្រី០២នាក់ ។
- ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ អនុប្រធានការិយាល័យ បានចូលរួមជាមួយក្រុមការងារ នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្មចុះតាមដានដំណើរការសហគមន៍កសិកម្មចំនួន០៤ នៅស្រុកអូរយ៉ាវ និងស្រុកលំផាត់ ។
- ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.បានចូលរួមពិធីចុះកិច្ចព្រមព្រៀងផ្តល់មូលនិធិICSO សម្រាប់គាំទ្រមុខរបរសហគមន៍កសិកម្មចម្រុះរតនល្មីនក្រែន និងសហគមន៍កសិកម្មអភិវឌ្ឍន៍លុងយុង នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួម៣៥នាក់ ស្រី០៣នាក់ ។
- ថ្ងៃទី១៩-២០ ខែវិច្ឆិកា ឆ្នាំ២០១៨ មន្ត្រី០២រូបបានសម្របសម្រួល វគ្គបណ្តុះបណ្តាលស្តីពីអភិបាលកិច្ចល្អ និងការគ្រប់គ្រងហិរញ្ញវត្ថុដល់ថ្នាក់ដឹកនាំសហគមន៍កសិកម្មចំនួន០២សហគមន៍ដោយមានអ្នកចូលរួមចំនួន ៣៥នាក់ ស្រី០៥នាក់ នៅសាលប្រជុំមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរីគាំទ្រដោយអង្គការICSO។
-

### ៤.៥. សកម្មភាពចូលរួមផ្សេង

- ថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៧ បានចូលរួមពិធីប្រគល់វិញ្ញាបនបត្រសម្គាល់ដីកម្មសិទ្ធិ សមូហភាពជូនសហគមន៍ជនជាតិដើមភាគតិចចំនួន០៣ភូមិគឺភូមិកាចាញ ភូមិកាលង ភូមិឡៃ ។
- ថ្ងៃទី១០ ខែមករា ឆ្នាំ ២០១៧ ចូលរួមប្រជុំស្តីពីការពិនិត្យ និងផ្តល់ការណែនាំអំពីការរៀបចំសេចក្តីព្រាងលក្ខន្តិកៈសហគមន៍ជនជាតិដើមភាគតិចព្រៅ នៅភូមិផាវ ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី ។
- ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៨ បានចូលរួមប្រជុំពេញអង្គស្តីពីការពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខន្តិកៈសហគមន៍ជនជាតិដើមកាចក់ភូមិអ៊ីន ស្ថិតនៅភូមិអ៊ីន ឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរិ ។

- ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៨ មន្ត្រី០១រូបបានចូលរួមប្រជុំឆ្លងផែនទីបឋមសហគមន៍ ជនជាតិដើមភាគតិចភូមិរ៉កនៅភូមិរ៉ក ឃុំកុកឡាក់ ស្រុកវើនសៃ ខេត្តរតនគិរី ដែលមានកសិករចូលរួមចំនួន៨០ ស្រី៣២នាក់ ។
- ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៨ ប្រជុំបូកសរុបការងារប្រចាំខែមីនា ឆ្នាំ២០១៨ ។
- ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ចូលរួមប្រជុំណែនាំពីផែនការថវិកា២០១៩-២០២១ ដែលមានអ្នកចូលរួម ២១នាក់ ស្រី០២នាក់
- ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ ប្រជុំប្រចាំខែឧសភា នៅការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម ដែលមានអ្នកចូលរួម០៤នាក់ ស្រី០០នាក់ ។
- ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៨ អនុប្រធានការិយាល័យ បានចូលរួមប្រជុំពីការធ្វើផែនការឆ្នាំ២០១៩ ដែលមានអ្នកចូលរួម១៨នាក់ ស្រី០០នាក់ ។
- ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨ ចូលរួមប្រជុំស្ដីពីការពិនិត្យផែនការយុទ្ធសាស្ត្រ២០១៩-២០២១ នៅមន្ទីរកសិកម្មខេត្តរតនគិរី ។
- ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ ចូលរួមប្រជុំត្រួតពិនិត្យការងារជាមួយនាយកដ្ឋានអភិវឌ្ឍន៍ ធនធានមនុស្ស នៅសាលប្រជុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី ។
- ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨ ចូលរួមប្រជុំផ្សព្វផ្សាយសេចក្ដីសម្រេចលេខ២៦៨ នៅសាលប្រជុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី ដែលមានអ្នកចូលរួម២០នាក់ស្រី០១ នាក់ ។
- ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ អនុប្រធានការិយាល័យរួមជាមួយលោកប្រធានមន្ទីរ បានទទួលស្វាគមន៍ក្រុមទស្សនៈកិច្ចសិក្សារបស់អង្គការសហការដើម្បីវិបុលភាព នៅសាលប្រជុំមន្ទីរកសិកម្ម ដែលមានអ្នកចូលរួម២៤នាក់ ស្រី១៩នាក់ ។
- ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ អនុប្រធានការិយាល័យនិងមន្ត្រី០១រូប បានចូលរួមជូនដំណើរក្រុមទស្សនៈកិច្ចសិក្សារបស់អង្គការសហការដើម្បីវិបុលភាពទៅមើលសហគន៍កសិកម្មចំនួន០៣សហគមន៍ ( សហគមន៍កសិកម្មចម្រុះឈ្នីនក្រែន សហគមន៍កសិកម្មឧត្តមមានជ័យដីឡូតិ៍ សហគមន៍កសិកម្មស្រែអង្រ្គងរីកចម្រើន )។
- ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨ ចូលរួមប្រជុំត្រួតពិនិត្យសកម្មភាពការងារតាមការិយាល័យក្រោមការដឹកនាំប្រជុំដោយលោកង៉ែត ធារ៉ា អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី ដែលមានការិយាល័យចូលរួមចំនួន០៣ការិយាល័យ(ការិ.អភិវឌ្ឍន៍សហគមន៍កសិកម្ម .ការិ.ផ្សព្វផ្សាយកសិកម្ម .ការិ.វិស្វកម្មកសិកម្ម)។
- ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៨ អនុប្រធានការិយាល័យបានចូលរួមប្រជុំបូកសរុបរបាយការណ៍ទឹកជំនន់នៅសាលប្រជុំមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួម១៦នាក់ ស្រី០១នាក់ ។

- ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ អនុប្រធានការិយាល័យ បានចូលរួមប្រជុំស្តីពីការគ្រប់គ្រងមន្ត្រីរាជការ នៅសាលប្រជុំមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួម១៧នាក់ ស្រី០១នាក់ ។
- ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨ អនុប្រធានការិយាល័យបានចូលរួមប្រជុំបូកសរុប របាយការណ៍ប្រចាំខែសីហា នៅសាលប្រជុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអ្នកចូលរួមសរុបចំនួន១៣នាក់ ស្រី០០ នាក់ ។
- ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៨ មន្ត្រី០១រូប បានចូលរួមសិក្ខាសមារណកម្មគម្រោងផែនការវិនិយោគឆ្នាំ២០១៩របស់ស្រុកអណ្តូងមាស នៅសាលាស្រុកអណ្តូងមាស ដោយមានអ្នកចូលរួម២៦នាក់ ស្រី០៦នាក់ ។
- ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៨ អនុប្រធានការិយាល័យបានចូលរួមប្រជុំពិនិត្យការងារ និងផែនការសម្រាប់ ត្រីមាសទី០៤ ដែលមានអ្នកចូលរួម១៨នាក់ ស្រី០១នាក់ ។
- ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨ អនុប្រធានការិយាល័យបានចូលរួម ប្រជុំលើកផែនការសកម្មភាពគម្រោងASPIRE នៅសាលប្រជុំមន្ទីរកសិកម្ម មានអ្នកចូលរួម០៩នាក់ ។
- ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៨ អនុប្រធានការិយាល័យចូលរួមប្រជុំស្តីពីគោលការណ៍ណែនាំ និងអនុសាសន៍របស់រដ្ឋមន្ត្រី ដឹកនាំប្រជុំដោយលោកប្រធានមន្ទីរកសិកម្ម ដែលមានអ្នកចូលរួម២០នាក់ ។
- ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ចូលរួមប្រជុំត្រួតពិនិត្យសកម្មភាពការងារក្រោមអធិបតីភាពឯ.ឧ គឹម ស៊ុន អគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
- ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៨ ចូលរួមពិធីសំណេះសំណាលក្រោមអធិបតីភាពឯ.ឧ ម៉ាន សុគ្រី រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមប្រជុំបូកសរុបរបាយការណ៍ប្រចាំខែតុលា នៅសាលប្រជុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដឹកនាំប្រជុំដោយលោក សយ សូណា ដោយការចូលរួមពីលោកអនុប្រធានមន្ទីរ ថ្នាក់ដឹកនាំខណ្ឌរដ្ឋបាលព្រៃឈើ/ រដ្ឋបាលជលផលនិងការិយាល័យចំណុះ របស់មន្ទីរសរុបចំនួន ១៦នាក់ ។
- ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមកិច្ចប្រជុំពេញអង្គរបស់ សហគមន៍ដើម្បី ត្រួតពិនិត្យនិងអនុម័តលើខ្លឹមសារព្រាងបទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ សហគមន៍ជនជាតដើមព្រៅ នៅភូមិជួយ ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ដែលមានអ្នកចូលរួមប្រមាណ១៣០នាក់ ស្រី២៩នាក់ ។
- ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមកិច្ចប្រជុំពេញអង្គរបស់សហគមន៍ដើម្បីត្រួតពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ សហគមន៍ជនជាតដើមព្រៅ នៅភូមិតាបូក ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ដែលមានអ្នកចូលរួមប្រមាណ៩០នាក់ ស្រី៣៦នាក់ ។

- ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ មន្ត្រី០១រូបចូលរួមកិច្ចប្រជុំពេញអង្គរបស់សហគមន៍ដើម្បីត្រួតពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ញាផ្ទៃក្នុងស្តីពីការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិសហគមន៍ជនជាតិដើមព្រៅ នៅភូមិភ្លឺធំ ឃុំតាវែងលើ ស្រុកតាវែង ខេត្តរតនគិរី ដែលមានអ្នកចូលរួមប្រមាណ ៥៥នាក់ ស្រី២១នាក់ ។
- ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ មន្ត្រីចំនួន០២រូបសហការណ៍ជាមួយគម្រោងជម្រុញទីផ្សារកសិកម្មខ្នាតតូចរបស់មន្ទីរពាណិជ្ជកម្មបានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំដំឡូងមីដល់កសិករ នៅភូមិជ្រុង ឃុំកិះចុង ស្រុកបរកែវ ដែលមានកសិករចូលរួមចំនួន ៦៥នាក់ ស្រី២៥នាក់ ។
- ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ មន្ត្រីចំនួន០២រូបសហការណ៍ជាមួយគម្រោងជម្រុញទីផ្សារកសិកម្មខ្នាតតូច របស់មន្ទីរពាណិជ្ជកម្មបានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំដំឡូងមីដល់កសិករ នៅភូមិលើហាន់ ឃុំកិះចុង ស្រុកបរកែវ ដែលមានកសិករចូលរួមចំនួន ៨៩នាក់ ស្រី៥៧នាក់ ។
- ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ មន្ត្រីចំនួន០២រូបសហការណ៍ជាមួយគម្រោងជម្រុញទីផ្សារកសិកម្មខ្នាតតូច របស់មន្ទីរពាណិជ្ជកម្មបានផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសដំណាំដំឡូងមីដល់កសិករ នៅភូមិសោមត្រក ឃុំសោមធំ ស្រុកអូរយ៉ាដាវ ដែលមានកសិករចូលរួមចំនួន ៩៤នាក់ ស្រី៥៧នាក់ ។
- ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.បានចូលរួមប្រជុំប្រឹក្សាយោបល់កំណត់ព្រំប្រទល់ផែនទីគំនូសដោយដៃ របស់ភូមិតាហ៊ើយ ដើម្បីត្រៀមចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចនៅសាលាឃុំតឺន ស្រុកកូនមុំ ដែលមានអ្នកចូលរួម៣៦នាក់ ស្រី០៨នាក់។
- ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.បានចូលរួមប្រជុំប្រឹក្សាយោបល់កំណត់ព្រំប្រទល់ផែនទីគំនូសដោយដៃរបស់ភូមិតឺន ដើម្បីត្រៀមចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចនៅសាលា ឃុំតឺន ស្រុកកូនមុំ ដែលមានអ្នកចូលរួម៣២នាក់ ស្រី១២នាក់។
- ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨ មន្ត្រី០១រូបបានចូលរួមប្រជុំប្រឹក្សាយោបល់កំណត់ ព្រំប្រទល់ផែនទីគំនូសដោយដៃរបស់ភូមិខ្មែង ដើម្បីត្រៀមចុះបញ្ជីដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចនៅសាលាឃុំប៉ូយ ស្រុកអូរជុំ ដែលមានអ្នកចូលរួម៤២នាក់ ស្រី១៨នាក់។
- ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.បានប្រជុំឆ្លងផែនការថវិការបស់គម្រោងASPIRE នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដែលមានអ្នកចូលរួម២០នាក់ ស្រី០២នាក់ ។
- ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមប្រជុំបូកសរុបរបាយការណ៍ប្រចាំខែតុលា នៅសាលប្រជុំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ដឹកនាំប្រជុំដោយលោក សយ សូណា ដោយការចូលរួម លោកអនុប្រធានមន្ទីរ ថ្នាក់ដឹកនាំខណ្ឌរដ្ឋបាលព្រៃឈើ/រដ្ឋបាលជលផល និងការិយាល័យចំណុះ របស់មន្ទីរ សរុបចំនួន ១៦នាក់ ។

- ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមកិច្ចប្រជុំស្តីពីការបង្កើតផ្សារសហគមន៍កសិកម្ម ដឹកនាំប្រជុំដោយលោក សយ សុណា និងមានការចូលរួមពីតំណាងអង្គការសេដាក ឌីភីអេ អាយស៊ីអេសអូ ។
- ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ អនុប្រធានការិ.ចូលរួមកិច្ចប្រជុំពេញអង្គរបស់សហគមន៍ដើម្បីត្រួតពិនិត្យ និងអនុម័តលើខ្លឹមសារព្រាងបទបញ្ជាផ្ទៃក្នុងស្តីពីការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិសហគមន៍ជនជាតិដើមព្រៅ នៅភូមិការទៀង ឃុំល្បាំង០១ ស្រុកលំផាត់ ខេត្តរនគិរី ដែលមានអ្នកចូលរួមប្រមាណ ៨៦នាក់ ស្រី៤១នាក់ ។

**៥. ការគ្រប់គ្រងសហគមន៍**( ជូនភ្ជាប់នូវតារាងទិន្នន័យសហគមន៍កសិកម្ម)

| ល.រ | ស្រុក | ចំនួនសហគមន៍ | គាំទ្រដោយRULIP | គាំទ្រដោយDPA |
|---|---|---|---|---|
| ១ | កូនមុំ | ១២ | ៣ | ៩ |
| ២ | លំផាត់ | ០៨ | ៥ | ៣ |
| ៣ | អូរជុំ | ០៧ | ៦ | ១ |
| ៤ | បរកែវ | ០៥ | ០៥ | ០ |
| ៥ | អូរយ៉ាដាវ | ០៦ | ០៦ | ០ |
| ៦ | អណ្តូងមាស | ០១ | ០ | ១ |
| សរុប | | ៣៩ | ២៥ | ១៤ |

**៦.កិច្ចសហការណ៍ជាមួយអង្គការដៃគូ**

- អង្គការDPA ជួយបន្តការគាំទ្រសហគមន៍កសិកម្មចំនួន១0សហគមន៍
- អង្គការICSO ជួយគាំទ្រ សហគមន៍កសិកម្មចំនួន0២សហគមន៍

**៧.បញ្ហាជួបប្រទះ**

**៧.១.សហគមន៍កសិកម្ម:**

- ថ្នាក់ដឹកនាំសហគមន៍មួយចំនួននៅមិនទាន់ចេះរៀបចំផែនការសកម្មភាព និងផែនការមុខជំនួញបានត្រឹមត្រូវ
- សមត្ថភាពដឹកនាំនិងការគ្រប់គ្រងរបស់អ្នកដឹកនាំសហគមន៍កសិកម្មនៅមានកម្រិត
- ការប្រជុំប្រចាំខែរបស់ថ្នាក់ដឹកនាំមិនសូវទៀងទាត់

- ថ្នាក់ដឹកនាំមិនទាន់យល់ពីការស្វែងរកទីផ្សារលក់កសិផលបានថ្លៃ
- សហគមន៍មិនទាន់អាចផលិតកសិផលមានគុណភាពតាមតម្រូវការស្តង់ដាទីផ្សារ
- សមាជិកសហគមន៍កសិកម្មនៅមិនទាន់យល់ច្បាស់ពីសិទ្ធិនិងកាតព្វកិច្ចរបស់ខ្លួន
- សហគមន៍កសិកម្មនៅមិនទាន់មានបណ្តាញមុខជំនួញជាមួយគ្នា

**៧.២.ការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម**

- មិនមានសម្ភារៈការិយាល័យគ្រប់គ្រាន់
- ថវិកាសម្រាប់គាំទ្រសហគមន៍កសិកម្មមិនគ្រាប់គ្រាន់
- ចំណេះដឹងរបស់មន្ត្រីមិនទាន់យល់ច្បាស់ពីបញ្ជីគណនេយ្យសហគមន៍កសិកម្ម

**៨.ផែនការបន្ត**

- បន្តពង្រឹងសហគមន៍កសិកម្ម
- ជម្រុញការអភិវឌ្ឍន៍មុខជំនួញរបស់សហគមន៍កសិកម្ម
- ជម្រុញការរៀបចំសន្និបាតប្រចាំរបស់សហគមន៍កសិកម្ម
- បន្តកិច្ចសហការណ៍ជាមួយអង្គការដៃគូ

ជ. ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍កសិកម្ម

ឈាង ណូរ៉ា